**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី ៣**

**ថ្ងៃទី ០២-០៣ ខែមិថុនា ឆ្នាំ ២០១០**

# សេចក្តីជូនព័ត៌មាន

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់មគ្គុទេសក៏ដល់ភាពជាដៃគូសម្រាប់ការអភិវឌ្ឍន៍កម្ពុជា

***រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០:*** វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ បានប្រារព្ធឡើងនៅរាជធានីភ្នំពេញ នាថ្ងៃទី០២- ០៣ ខែមិថុនា ឆ្នាំ ២០១០ ។ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ជាវេទិកាកម្រិតខ្ពស់សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពិនិត្យរួមគ្នាអំពីវឌ្ឍនភាព បញ្ហាប្រឈម និងកំណត់នូវសកម្មភាពជាយុទ្ធសាស្ត្រ សម្រាប់ឈានទៅសម្រេចបណ្តាគោលដៅអភិវឌ្ឍន៍ ដូចមានចែងក្នុង ***យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២*** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស-វត្សរ៍កម្ពុជា ។ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា បានឆ្លុះបញ្ចាំងពីភាពដឹកនាំរបស់រាជរដ្ឋាភិបាល លើរបៀបវារៈនៃកិច្ចអភិវឌ្ឍន៍ប្រទេស ទន្ទឹមនឹងការពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ។

ប្រធានបទស្នូលនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ៣ ឆ្នាំ ២០១០ នេះ គឺ « *ការអនុវត្តន៍* ***យុទ្ធសាស្ត្រចតុកោណ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព - ដំណាក់កាលទី២*** *តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម»* ។ ប្រធានបទនេះបានផ្តល់លទ្ធភាពឱ្យមានការពិភាក្សាលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ដែលត្រូវបន្តអាណត្តិកាលរបស់ខ្លួនរហូតដល់ឆ្នាំ ២០១៣ និងបានកំណត់មាគ៌ាសម្រាប់ការហក់ឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក្នុងកម្រិតខ្ពស់ និងប្រកបដោយចីរភាព បន្ទាប់ពីដំណើរឆ្លងកាត់កលិយុគហិរញ្ញវត្ថុ និងឱនភាពសេដ្ឋកិច្ចសកលលោក ។

វេទិកាបានយល់ស្របជាឯកច្ឆ័ន្ទថា ជោគជ័យនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ ការបន្តរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច អភិបាលកិច្ចល្អ និងបរិស្ថានកាន់តែអនុគ្រោះ ។ វេទិកាបានគូសបញ្ជាក់ពីសារៈសំខាន់នៃការសម្របសម្រួលការអនុវត្តន៍កម្មវិធីកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ពិសេសការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលសាធារណៈ ។ ដៃគូអភិវឌ្ឍន៍បានផ្តល់តួលេខណែនាំនៃការគាំទ្រហិរញ្ញប្បទាន ដែលមានទំហំប្រមាណជាងមួយពាន់លានដុល្លាអាមេរិក សម្រាប់ឆ្នាំ ២០១០ ។ ទន្ទឹមនេះ កម្រិតនៃការគាំទ្រសម្រាប់ឆ្នាំ ២០១១ និង ២០១២ ខាងមុខ ក៏អាចមានកម្រិតប្រហាក់ប្រហែលគ្នានឹងឆ្នាំ ២០១០ ដែរ ។ វេទិកាក៏បានអនុម័តិ **សូចនាករតាមដានរួមគ្នា** ចំនួន ២០ សម្រាប់ជាក្របខ័ណ្ឌអនុវត្តន៍ និងតាមដានលទ្ធផលក្នុងស្មារតីភាពជាដៃគូ កិច្ចសហប្រតិបត្តិការ និងគណនេយ្យភាព ។

*****

វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ បានប្រព្រឹត្តទៅក្រោមកិច្ចដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយឯកឧត្តម បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។ សមាជិក សមាជិការបស់រាជរដ្ឋាភិបាល និងតំណាងជាន់ខ្ពស់របស់ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល និងគណៈប្រតិភូសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ តំណាងឱ្យប្រទេស និងស្ថាប័នផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការចំនួន ២៥ និងតំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជន បានចូលរួមក្នុងវេទិកាលើកនេះ ។

ក្នុងកិច្ចស្វាគមន៍ជូនគណៈប្រតិភូនៃវេទិកា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** បានមានប្រសាសន៍ថា សន្តិភាព និងស្ថេរភាពសង្គម ដែលជាសមិទ្ធផលនៃការអនុវត្តន៍ «***គោលនយោបាយឈ្នះ - ឈ្នះ***» របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជម្រុញឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកម្ពុជា ។ ក្នុងការដឹកនាំប្រទេសដើម្បីជំនះឥទ្ធិពលជាអវិជ្ជមានដែលកម្ពុជាទទួលរងពីវិបត្តិកលិយុគហិរញ្ញវត្ថុ និងឱនភាពសេដ្ឋកិច្ចសកលលោក ក្នុងជំហានបន្ទាប់របស់ខ្លួន រាជរដ្ឋាភិបាលប្តេជ្ញាបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវកម្មវិធីកំណែទម្រង់ស្នូលដែលបានដាក់ចេញ ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** បានគូសបញ្ជាក់ក្នុងសុន្ទរកថាស្វាគមន៍ថា វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ បានផ្តល់នូវ «កាលានុវត្តភាព» សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ផ្លាស់ប្តូរយោបល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈម និងរួមគ្នាកំណត់សកម្មភាពគន្លឹះ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ច- សង្គម ដោយ « *ពង្រឹងភាពជាដៃគូ បង្កើនប្រសិទ្ធភាព និងគណនេយ្យភាពទ្វេទិសនៃធនធានសាធារណៈ*» ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។

ថ្លែងក្នុងចំណាប់អារម្មណ៍តំណាងឱ្យសហគមន៍ដៃគូអភិវឌ្ឍន៍ លោកស្រី Annette Dixon ប្រធានស្ថានតំណាងរបស់ធនាគារពិភពលោកប្រចាំកម្ពុជា បានបញ្ជាក់ថារាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ «មានគោលដៅរួមគ្នា» ក្នុងការសម្រេចឱ្យបាននូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍សម្រាប់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកងាយរងគ្រោះ ។ ជោគជ័យគឺអាស្រ័យលើប្រសិទ្ធភាពនៃភាពជាដៃគូរបស់យើង ។ លោកស្រីបានសង្កត់ធ្ងន់លើភាពចាំបាច់ដែលត្រូវធានាថា ការរីកលូតលាស់ឡើងវិញនៃសេដ្ឋកិច្ចជាតិ យកចិត្តទុកដាក់ដល់ការដោះស្រាយបញ្ហាសមធមិ ការធ្វើពិពិធកម្មមូលដ្ឋានកំណើន តម្លាភាព និងកែលំអសមត្ថភាពប្រកួតប្រជែង ក៏ដូចជាផ្តល់ការគាំពារសង្គម និងធានានិរន្តរភាព ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសបើកវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាជាផ្លូវការ ដោយបានថ្លែងសុន្ទរកថាគន្លឹះ និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់សម្រាប់ជាមគ្គុទេសក៍ដល់កិច្ចពិភាក្សារយៈពេលពីរថ្ងៃនៃវេទិកា ។ បន្ទាប់ពីបានស្វាគមន៍ដៃគូទាំងអស់ដែលបានចូលរួម **សម្តេចនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់នៅក្នុងសុន្ទរកថាគន្លឹះ លើប្រធានបទសំខាន់ៗ ចំនួន ៦ ចំណុច ÷

- ទីមួយផ្តោតទៅលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការងើបឡើងវិញនៃសេដ្ឋកិច្ចជាតិ បន្ទាប់ពីការធ្លាក់ចុះក្នុងពេលថ្មីៗ ដោយសង្កត់ធ្ងន់លើកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងដោយប្រុងប្រយ័ត្ននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ទ្រទ្រង់ដល់ការលូតលាស់របស់វិស័យឯកជនដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ ។ **សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការគោលនយោបាយសេដ្ឋកិច្ច ដែលធានាថាប្រជាជនទាំងអស់នឹងទទួលផលពីផ្លែផ្កាកំណើនសេដ្ឋកិច្ច ។

- ប្រធានបទទីពីរ ពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ។ **សម្តេចនាយករដ្ឋមន្ត្រី** គូសបញ្ជាក់ថា «អភិបាលកិច្ចល្អតម្រូវឱ្យមានការប្រតិបត្តិតាមវិធាននៃច្បាប់ ដោយសមភាព មានគណនេយ្យភាព និងតម្លាភាព» ដោយបានរំលេចអំពីវឌ្ឍនភាពដែលរាជរដ្ឋាភិបាលសម្រេចបាននៅតាមការដ្ឋានកំណែទម្រង់សំខាន់ៗ ដោយរួមទាំងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

- ប្រធានបទទីបី គឺស្តីអំពីតួនាទីដ៏សំខាន់នៃវិស័យកសិកម្មក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងការទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជន ។ **សម្តេចនាយករដ្ឋមន្ត្រី** បានកត់សំគាល់ពីសារៈសំខាន់នៃការធ្វើពិពិធកម្មវិស័យកសិកម្ម ព្រមទាំងបានថ្លែងថា នៅក្នុងរយៈពេលដ៏ខ្លីខាងមុខ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវឯកសារគោលនយោបាយមួយ *«ស្តីពីវិធានការជំរុញការផលិតស្រូវ និងការនាំចេញអង្ករ»* ។ ក្រៅពីនេះ រាជរដ្ឋាភិបាលនឹងរៀបចំនូវគោលនយោបាយដីធ្លីពេញលេញមួយ ដែលមានលក្ខណៈជា *«សៀវភៅស»* សម្រាប់ជាផែនទីចង្អុលផ្លូវលើការងារកែទម្រង់ដីធ្លី នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែងខាងមុខ ។

- ប្រធានបទគន្លឹះទីបួនដែលគូសបញ្ជាក់ដោយ **សម្តេចនាយករដ្ឋមន្ត្រី** ផ្តោតលើការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងផ្នែកឯកជន។ ការអនុវត្ត *«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥»* នឹងពង្រឹងវិសាលភាពនៃវិស័យហិរញ្ញវត្ថុ សម្រាប់ទ្រទ្រង់ដល់ដំណើរការសេដ្ឋកិច្ចឱ្យមានលក្ខណៈទំនើប ។ លើសពីនេះទៀត ការពង្រឹងយន្តការស្ថាប័ន និងបង្កើនវិនិយោគសាធារណៈសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ ជាសក្ខីភាពឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការ «បង្កើតនូវបរិស្ថានសមស្របដែលធានានូវស្ថិរភាព និងភាពអាចប៉ាន់ប្រមាណបាន ដើម្បីទាក់ទាញ និងលើកស្ទួយវិនិយោគឯកជន»។

- ប្រធានបទទីប្រាំ ផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍វិស័យសង្គមកិច្ច ។ **សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីមូលដ្ឋានទស្សនវិជ្ជារបស់រាជរដ្ឋាភិបាល ក្នុងការធានាសិទ្ធិក្នុងការទទួលបានការអប់រំ

សម្រាប់ទាំងអស់គ្នា ក៏ដូចជាតួនាទីនៃការអប់រំក្នុងការអភិវឌ្ឍន៍មូលដ្ឋានធនធានមនុស្សដែលចាំបាច់សម្រាប់សេដ្ឋកិច្ចជាតិ ។ ជាមួយគ្នាផងដែរចំពោះវិស័យសុខាភិបាល និងបញ្ហាយ៉េនឌ័រ **សម្តេចនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីទំនាក់ទំនងរវាងការធានាបាននូវសិទ្ធិមូលដ្ឋានរបស់ប្រជាជនទៅនឹងការបង្កើតលក្ខខណ្ឌដើម្បីទទួលបានវិបុលភាពសម្រាប់ទាំងអស់គ្នា ។

- ប្រធានបទចុងក្រោយដែល **សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ គឺភាពជាដៃគូ ដែល *«ជាកត្តាកំណត់ដ៏សំខាន់បំផុតមួយ នៅក្នុងកិច្ចប្រឹងប្រែងរបស់យើងទាំងអស់គ្នា ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅនៃ* ***យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២*** *»* ។

**សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា នៅក្នុងនីតិកាលទី៤នេះ «រាជរដ្ឋាភិបាលនឹងនៅតែបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនតទៅទៀត ដើម្បីដឹកនាំនាវាកម្ពុជាឱ្យបន្តធ្វើដំណើរលើមាគ៌ានៃការអភិវឌ្ឍន៍គ្រប់វិស័យ ក្នុងនោះមានការកាត់បន្ថយភាពក្រីក្រ ការពង្រឹងសុខសន្តិភាព និងស្ថិរភាពនយោបាយ អភិបាលកិច្ចល្អ កម្មវិធីកំណែទម្រង់នានា» ។

អង្គវេទិកាទាំងមូលបានស្វាគមន៍ចំពោះការអនុម័តិផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ដោយរដ្ឋសភា កាលពីថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១០ ។ វេទិកាបានឯកភាពលើវឌ្ឍនភាពគួរកត់សំគាល់ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា រួមមានការធ្លាក់ចុះនៃអត្រាស្លាប់របស់កុមារ ការកើនឡើងនៃអត្រាសិស្សចុះឈ្មោះចូលរៀន ការទទួលបានការថែទាំនិងព្យាបាលសម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងការប្រើប្រាស់ទឹកស្អាត ។ ទន្ទឹមនេះក៏ឯកភាពថាត្រូវបង្កើនល្បឿនបន្ថែមទៀត ដើម្បីឈានទៅសម្រេចគោលដៅមួយចំនួនទៀតដែលពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភ ដោយផ្តោតការយកចិត្តទុកដាក់លើសន្តិសុខស្បៀងក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍វិស័យសុខាភិបាល ។ វេទិកាឯកភាពលើភាពចាំបាច់ដែលត្រូវបន្តកិច្ចប្រឹងប្រែងបន្ថែមទៀត ស្តីពីការអប់រំនៅកម្រិតបឋមសិក្សា កាត់បន្ថយអត្រាមរណៈរបស់មាតា និងធានាចីរភាពបរិស្ថាន ដោយរួមទាំងបញ្ហាទឹកស្អាតនិងអនាម័យ ។ វេទិកាបានឯកភាពលើចំណុចគន្លឹះចម្បង ចំនួន ៣ ចំណុចបន្ថែមទៀត គឺ : រៀបចំបញ្ចប់សូចនាករ និងក្របខ័ណ្ឌតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ធ្វើសុខដុមនីយកម្មការងារផែនការ ថវិកា និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបន្តអនុវត្តន៍កម្មវិធីកែទម្រង់ស្នូល ដើម្បីគាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

វេទិកាបានផ្តល់ការគាំទ្រជាឯកច្ឆ័ន្ទលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តគោលនយោបាយ រក្សាឱ្យបានគង់មាំនូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តកាន់តែស៊ីជម្រៅ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីកែទម្រង់នេះ គឺជាក្របខ័ណ្ឌ សម្រាប់ការសម្របសម្រួល និងពិភាក្សាដោយផ្តោតលើលទ្ធផល រវាងក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល និងរវាងរាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍ ។ វេទិកាបានឯកភាពលើភាពចាំបាច់ត្រូវបន្តកែលំអការគ្រប់គ្រងដោយតម្លាភាព និងដោយប្រសិទ្ធភាពនូវចំណូលដែលបានមកពីវិស័យប្រេង និងឧស្ម័ន ។ វិស័យឯកជនត្រូវបានទទួលស្គាល់ថាជាចលករនៃកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ ក្នុងន័យនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺផ្តោតលើការបន្តពង្រឹងមូលដ្ឋានដែលមានស្រាប់ សម្រាប់ការអភិវឌ្ឍន៍វិស័យឯកជន និងការបង្កើតនូវលក្ខខ័ណ្ឌអំណោយផល ធនធាន

មនុស្ស និងហេដ្ឋារចនាសម្ព័ន្ធសមស្រប សម្រាប់ការកកើតឡើងនូវឧស្សាហកម្មថ្មីៗ ។ វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន ត្រូវបានទទួលស្គាល់ថាជាកិច្ចប្រតិបត្តិល្អជាអន្តរជាតិ ហើយរាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តយន្តការនេះបន្តទៅទៀត ។

ពាក់ព័ន្ធនឹងការលើកកំពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម ដែលជាអាទិភាពសំខាន់សម្រាប់សេដ្ឋកិច្ចជាតិទាំងមូល ក៏ដូចសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់លាននាក់ វេទិកាបានកំណត់ចំណុចគន្លឹះ ៤ ជាអាទិភាព គឺ÷ ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាការកសាង និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធទីផ្សារនិងហិរញ្ញវត្ថុ ការពង្រីកសេវាស្រាវជ្រាវនិងផ្សព្វផ្សាយ ការផ្តោតការយកចិត្តទុកដាក់ទៅលើកសិកម្មមានលក្ខណៈធុរកិច្ច ពិពិធកម្ម និងការធ្វើពាណិជ្ជកម្ម រួមទាំងការរៀបចំស្តង់ដារ និងតម្លាភាព និងសមធម៌នៃការទទួលបានធនធាន សម្រាប់ផលិតកម្ម ដូចជា ដីធ្លី មូលធន និងធាតុចូលដទៃទៀត ។

វេទិកាបានយល់ស្របអំពីវិចារណញ្ញាណនៃការកំណត់ជាអាទិភាព នូវតម្រូវការនៃយុទ្ធសាស្ត្រជាតិសុវត្ថិភាពសង្គមមួយ ដូចដែល **សម្តេចនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងសុន្ទរកថាគន្លឹះប្រកាសបើកវេទិកា : «ក្នុងដំណើរឆ្លងកាត់ដំណាក់កាលដ៏លំបាកបំផុតនៃវិបត្តិកន្លងមកនេះ កម្ពុជាប្រមូលផ្តុំបាននូវមេរៀន និងបទពិសោធន៍ជាច្រើន ។ ឈានចេញពីមេរៀន និងបទពិសោធន៍ទាំងនេះ យើងបានមើលឃើញអំពីសេចក្តីត្រូវការក្នុងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈគត់មត់ គ្រប់ជ្រុងជ្រោយ និងសមស្របទៅតាមសមត្ថភាព និងសេចក្តីត្រូវការរបស់កម្ពុជា » ។

វត្តមានរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** បានផ្តល់ជាកិត្តិយសដល់វេទិកា ក្នុងការពិភាក្សាលើប្រធានបទស្តីពីការអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាការគូសបញ្ជាក់យ៉ាងមុតមាំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍កំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ ។ វេទិកាបានយល់ស្របជាឯកច្ឆ័ន្ទថា កំណែទម្រង់នេះ មិនមែនជាកំណែទម្រង់ដែលប្រើប្រាស់ «វិធីសាស្ត្ររាជរដ្ឋាភិបាលទាំងមូល» (whole-of-government) ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំង «វិធីសាស្ត្ររួមរបស់ដៃគូអភិវឌ្ឍន៍» (whole-of-development partner) ផងដែរ ។ នៅពេលដែលផែនការអនុវត្តសម្រាប់រយៈពេល ៣ ឆ្នាំ នៃកម្មវិធីជាតិ ២០១០-២០១៩ ត្រូវបានរៀបចំរួចហើយ ភាគីពាក់ព័ន្ធទាំងអស់បានប្តេជ្ញាធានាអំពីសង្គតិភាព និងការបន្ស៊ីការផ្តល់ការគាំទ្រ និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ធនធាន ។

វេទិកាបានសំដែងអំណរគុណចំពោះការដឹកនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ក៏ដូចជាបញ្ហាគណនេយ្យភាព និងការប្រឆាំងអំពើពុករលួយ ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានសង្កត់ធ្ងន់ថា អភិបាលកិច្ចល្អ និងនីតិរដ្ឋ គឺជាស្នូលនៃ ***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាល ។ វឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់រួមមាន÷ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ច្បាប់ប្រឆាំអំពើពុករលួយត្រូវបានប្រកាសឱ្យប្រើរួចហើយ ។ យន្តការ ធនធានហិរញ្ញប្បទាន និងធនធានមនុស្សកំពុងត្រូវបានរៀបចំឡើងដើម្បីអនុវត្តច្បាប់នេះ ។ ពាក់ព័ន្ធកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ត្រូវបានប្រកាសឱ្យប្រើ ។ អាទិភាពជាបន្ត គឺបន្តពង្រឹងក្របខ័ណ្ឌច្បាប់ (ការបញ្ចប់ការតាក់តែងច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃប្រព័ន្ធ

តុលាការ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការងារពាក់ព័ន្ធនឹងការរៀបចំក្រមរដ្ឋបាល និងនីតិវិធីរដ្ឋបាល) ។ ដោយឡែក សម្រាប់កំណែទម្រង់រដ្ឋបាល វិធានការនានាត្រូវបានដាក់ឱ្យអនុវត្តដើម្បីធានាតម្លាភាពក្នុងការផ្ដល់សេវាសាធារណៈ រួមមានការផ្សព្វផ្សាយនូវ «កម្រងឯកសារស្ដីពីការផ្ដល់សេវាសាធារណៈ» ។ «ចំណាយប្រតិបត្តិការអាទិភាព» ដែលជាយន្តការអន្តរកាលចំពោះមុខ នឹងត្រូវរៀបចំបញ្ចប់នៅដំណាច់ខែមិថុនានេះ ហើយការពិនិត្យឡើងវិញនឹងត្រូវធ្វើឡើងនៅមុនពេលវេទិកាលើកបន្ទាប់ ក្នុងក្របខ័ណ្ឌនៃការតាមដានវឌ្ឍនភាពកំណែទម្រង់រដ្ឋបាលសាធារណៈ ។ កំណែទម្រង់ប្រព័ន្ធលាភការសម្រាប់រយៈពេលវែង ដែលនឹងត្រូវរៀបចំឡើងដំណាលគ្នានេះ ចាំបាច់ត្រូវរៀបចំជាជំហានៗឱ្យបានស្របនឹងលទ្ធភាពខាងធនធានដែលមាន និងគោលការណ៍ស្ដីពីចីរភាព ។

វេទិកាបានឯកភាពអំពីភាពចាំបាច់ ដែលត្រូវផ្ដោតការយកចិត្តទុកដាក់ដល់កិច្ចប្រឹងប្រែងរយៈពេលវែងដើម្បីធានាឱ្យមានរដ្ឋបាលសាធារណៈមួយដែលមានសមត្ថភាពរឹងមាំ ផ្អែកលើគោលការណ៍សមធម៌ ឯកភាពចីរភាព ស្នាដៃ តម្លាភាពនិងសមត្ថភាពការងារ ។ ធ្វើដូចនេះ ទើបរដ្ឋបាលសាធារណៈអាច «បម្រើប្រជាពលរដ្ឋបានល្អប្រសើរ» ។

វេទិកាបានឯកភាពថា ជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ស្ថិតនៅលើសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលការអនុវត្តន៍កម្មវិធីកំណែទម្រង់អន្តរវិស័យ និងប្រសិទ្ធភាពនៃភាពជាដៃគូ ។ ការពិភាក្សាអំពីការជម្រុញប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ បានចាត់ទុកថា ការគ្រប់គ្រងនិងដឹកនាំការអនុវត្តន៍កម្មវិធីកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីជាតិ ការធ្វើសុខដុមនីយកម្មរវាងការងារផែនការ និងថវិកា និងសង្គតិភាពនៃការផ្ដល់ហិរញ្ញប្បទានរបស់ដៃគូ គឺជាអាទិភាពគន្លឹះ ។ វេទិកាបានឯកភាពថា ការបង្កើនការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គឺជាការឆ្លើយតបនឹងភាពចាំបាច់ក្នុងការគ្រប់គ្រង និងការសម្របសម្រួលដៃគូដែលមានចំនួនច្រើន ហើយនេះក៏ជាអភិក្រមមួយសម្រាប់ពង្រឹងកិច្ចសហការរវាងបណ្ដាក្រសួងនិងស្ថាប័ននានានៃរាជរដ្ឋាភិបាល និងជាមួយអង្គការសង្គមស៊ីវិលផងដែរ ។

ដោយគូសបញ្ជាក់អំពីគោលការណ៍នៃភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍គឺជាស្នូលនៃវេទិកា ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** បានដឹកនាំកិច្ចដំណើរការ និងកិច្ចពិភាក្សារបស់អង្គវេទិកា ដោយបង្ហាញអំពីតួនាទីដ៏សំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ជាតិ និងអំពីភាពចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន ក៏ដូចជាកិច្ចសហការរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងការឈានទៅសម្រេចគោលដៅរួមដែលបានឯកភាពគ្នា ។ វេទិកាបានឯកភាពលើសំណើជាក់ស្ដែងជាច្រើន ដើម្បីធានាប្រសិទ្ធភាព និងការសម្របសម្រួលឱ្យបានប្រសើរក្នុងការប្រើប្រាស់ធនធាន ស្របតាមការប្ដេជ្ញាកន្លងមករវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ វេទិកាបានឯកភាពលើតារាង *សូចនាករតាមដានរួមគ្នា* ដែលគ្របដណ្ដប់លើវិស័យ និងការដ្ឋានកំណែទម្រង់គន្លឹះៗរបស់រាជរដ្ឋាភិបាល ដែលត្រូវអនុវត្ត និងតាមដានរួមគ្នាចាប់ពីវេទិកាលើកនេះរហូតដល់វេទិកាលើកក្រោយតាមរយៈយន្តការនៃកិច្ចប្រជុំដែលមានស្រាប់រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

វេទិកាទទួលស្គាល់សារៈសំខាន់នៃក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ ដែលជាឧបករណ៍សម្រាប់គាំទ្រដល់ដំណើរការរៀបចំផែនការ និងថវិកា ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតវិស័យ ។ ក្របខ័ណ្ឌហិរញ្ញប្បទានក៏បានរួមចំណែកផងដែរ ក្នុងការជម្រុញភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។ តួលេខណែនាំស្តីពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ បានបង្ហាញអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ការប្តេជ្ញាស្តីពីការបង្កើនភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទាន ដូចមានចែងក្នុង«ផែនការសកម្មភាពទីក្រុងអាក្រា» ដែលនេះជាក្របខ័ណ្ឌសម្រាប់ជម្រុញប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ដៃគូអភិវឌ្ឍន៍បានប្រកាសផ្តល់ការគាំទ្រប្រមាណជាងមួយពាន់លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១០ និងអាចមានកម្រិតប្រហាក់ប្រហែល សម្រាប់ឆ្នាំ២០១១ និងឆ្នាំ២០១២ ។

វេទិកាឯកភាពថា បញ្ហាប្រឈមដែលកម្ពុជាកំពុងជួបប្រទះនាពេលបច្ចុប្បន្ន គឺការធានាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ក្នុងពេលដែលស្ថានភាពសកលលោកនៅមិនទាន់មានភាពប្រាកដប្រជានៅឡើយ និងការបន្តគាំទ្រដល់ការអភិវឌ្ឍន៍ជនបទ ការធ្វើពិពិធកម្មកសិកម្ម និងការផ្តល់ការគាំពារសង្គមដល់ប្រជាជនក្រីក្រ ។ ជោគជ័យនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា នឹងអាស្រ័យដោយប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលក្នុងការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ការអនុវត្តន៍កម្មវិធីនៅកម្រិតវិស័យ និងការបន្តជម្រុញការអនុវត្តន៍ការដ្ឋានកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។ ដៃគូអភិវឌ្ឍន៍បានប្រកាសការប្តេជ្ញារបស់ខ្លួនក្នុងការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលបន្តទៀត ។

ចំណុចដែលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នេះ នឹងត្រូវអនុវត្តតាមរយៈក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ រីឯការតាមដានវឌ្ឍនភាពត្រូវអនុវត្តដោយទៀងទាត់ តាមរយៈគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ វេទិកាបានឯកភាពថា វេទិកាលើកទី៤នឹងប្រព្រឹត្តទៅនាដំណាច់ឆ្នាំ២០១១នៅរាជធានីភ្នំពេញ ។

---

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមអាស័យដ្ឋានអ៊ីម៉េល cdcf@crdb.gov.kh ឬគេហទំព័រ www.cdc-crdb.gov.kh ។